# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៤០៩ សហវ-ទស

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**

**កម្មវត្ថុ:** សំណើសុំគោលការណ៍ចំណាយថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» ជូននាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម ចំនួន ៦ ៨៤៩ ១២៥ ៨៨២ រៀល សម្រាប់ស្តារប្រឡាយ និងសាងសង់សំណង់សិល្បការលើប្រឡាយមេកណ្តាល ក្នុងឃុំឫស្សីក្រោក ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

**យោង:** - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- លិខិតលេខ ០៤៣ ធទឧ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹកនិងឧតុនិយម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមផ្តល់ជានាចំណាយជូនចំនួន ៦ ៦៧១ ០០០ ០០០ រៀល (ប្រាំមួយពាន់ប្រាំមួយរយចិតសិបមួយលានរៀលគត់) ដោយប្រើប្រាស់ឥណទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» សម្រាប់ឲ្យនាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម អនុវត្តការងារស្តារប្រឡាយ និងសាងសង់សំណង់សិល្បការលើប្រឡាយមេកណ្តាល ក្នុងឃុំឫស្សីក្រោក ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ រួមមាន:

- ស្តារប្រឡាយមេប្រវែង ៨.០០០ម និងដាំស្មៅតាមជើងទេរប្រឡាយមេសងខាងប្រវែង ៨.០០០ម
- ក្រាលក្រួសក្រហមលើខ្នងភ្លឺប្រឡាយខាងស្តាំ ប្រវែង ៨.០០០ម
- សាងសង់សំណង់ទ្វារទឹកលើប្រឡាយមេ( ទ្វារ២ ) ចំនួន ០៣កន្លែង
- សាងសង់សំណង់លូជ្រុងលើប្រឡាយមេ ចំនួន ០២កន្លែង
- ចាក់បេតុងជើងទេរប្រឡាយមេសងខាងស្ពានឆ្លងផ្លូវជាតិប្រវែង ៣០ម ចំនួន ០១កន្លែង
- សាងសង់សំណង់លូយកទឹកលើប្រឡាយមេមុខកាត់ ១ម ចំនួន ០៤ កន្លែង
- សាងសង់សំណង់លូដោះទឹកលើប្រឡាយមេមុខកាត់ ០,៨០ម ចំនួន ១៨ កន្លែង
- សាងសង់សំណង់លូដោះទឹក ២ជួរ លើប្រឡាយមេមុខកាត់ ០,៨០ម ចំនួន ០៦ កន្លែង

សេចក្តីដូចបានជម្រាបខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្តបន្ទាយមានជ័យ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ
- នាយកដ្ឋានវិស្វកម្មក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីមុខការ »
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com